ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

# សេចក្តីថ្លែងការណ៍

នាព្រឹកថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២៥ វេលាម៉ោងប្រហែល ៥:០០នាទី យោធាថៃបានបើកការបាញ់ប្រហារមកលើទឹកដីកម្ពុជា នៅក្នុងតំបន់អានសេះ ខេត្តព្រះវិហារ បន្ទាប់មកបាញ់នៅប្រាសាទតាមាន់ធំ និងទីតាំងផ្សេងទៀតតាមបណ្តោយព្រំដែន ដោយប្រើប្រាស់អាវុធធុនធ្ងន់ជាច្រើន។ រហូតដល់ម៉ោង ៧:០០នាទីព្រឹកថ្ងៃដដែល ការវាយប្រហារដោយយោធាថៃបានបន្តមកដល់តំបន់ជុំវិញនិងទីតាំងផ្ទាល់ប្រាសាទព្រះវិហារ ដោយបានបំផ្លាញអគារអភិរក្សរបស់គម្រោងអភិរក្សនិងជួសជុលគោបុរៈទី៥ ប្រាសាទព្រះវិហារ ក្រោមកិច្ចសហប្រតិបត្តិការកម្ពុជា-ឥណ្ឌា ដែលស្ថិតនៅបរិវេណគោបុរៈទី៥ និងហេដ្ឋារចនាសម្ព័ន្ធអភិរក្សដទៃទៀត។

ចាប់តាំងពីប្រាសាទព្រះវិហារត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៨ ភាគីថៃបានបង្កើតលេសនិងបង្កជម្លោះប្រដាប់អាវុធនៅតំបន់ប្រាសាទព្រះវិហារជាច្រើនលើកច្រើនសារនៅចន្លោះឆ្នាំ២០០៨ និងឆ្នាំ២០១១ ព្រមទាំងបានបង្កជម្លោះសារជាថ្មីនៅថ្ងៃទី២៤-២៨ ខែកក្កដា ឆ្នាំ២០២៥។ ការវាយប្រហារនេះធ្វើឡើងបន្ទាប់ពីយោធាថៃបានធ្វើសកម្មភាពបង្កហេតុជាច្រើនរាប់មិនអស់និងជាច្រើនថ្ងៃមកហើយ ជាពិសេសឧបទ្ទវហេតុកាលពីថ្ងៃម្សិលមិញនៅចំណុចព្រលានថ្ម ក្នុងតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ ស្ថិតក្នុងឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ក្នុងចេតនាញុះញង់ឱ្យមានការប៉ះទង្គិចគ្នាជាមួយបំណងបំផ្លាញកិច្ចព្រមព្រៀងសន្តិភាពទីក្រុងកូឡាឡាំពួរ។

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សូមថ្កោលទោសចំពោះការបង្កហេតុសារជាថ្មីម្តងទៀតនៅតំបន់ប្រាសាទព្រះវិហារដែលបានបង្កការលំបាកយ៉ាងធ្ងន់ធ្ងរដល់កិច្ចខិតខំប្រឹងប្រែងអភិរក្សប្រាសាទព្រះវិហារ និងការជម្លៀសមន្ត្រី បុគ្គលិក ឆ្មាំពលករ របស់អាជ្ញាធរជាតិព្រះវិហារ ព្រមទាំងប្រជាពលរដ្ឋនៅក្នុងតំបន់ទៅកាន់ទីកន្លែងសុវត្ថិភាព។ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សូមថ្កោលទោសយ៉ាងម៉ឺងម៉ាត់ចំពោះការរំលោភបំពានសេចក្តីថ្លែងការណ៍រួមស្តីពីកិច្ចព្រមព្រៀងសន្តិភាពរវាងកម្ពុជានិងថៃ ដែលបានចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រីនៃប្រទេសទាំងពីរ ក្រោមការសម្របសម្រួល និងធ្វើជាសាក្សីដោយលោក Donald Trump ប្រធានាធិបតីសហរដ្ឋអាមេរិក និងលោក Anwar Ibrahim នាយករដ្ឋមន្ត្រីនៃប្រទេសម៉ាឡេស៊ីកាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៥ នៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី។

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សូមអំពាវនាវភាគីថៃឱ្យបញ្ឈប់រាល់អរិភាពជាបន្ទាន់ ដែលគំរាមកំហែងដល់សន្តិភាពនិងស្ថិរភាពនៅក្នុងតំបន់ ហើយងាកមកគោរពកិច្ចព្រមព្រៀមបទឈប់បាញ់ សេចក្តីថ្លែងការណ៍រួមស្តីពីកិច្ចព្រមព្រៀងសន្តិភាពនិងកាតព្វកិច្ចទាំងឡាយនៅក្រោមច្បាប់អន្តរជាតិឱ្យបានម៉ឺងម៉ាត់ ស្មោះត្រង់ និងដោយសុច្ចន្ទៈពិតប្រាកដ។

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ អំពាវនាវឱ្យសហគមន៍អន្តរជាតិថ្កោលទោសចំពោះសកម្មភាពឈ្លានពានរបស់ភាគីថៃមកលើបូរណភាពទឹកដីរបស់កម្ពុជា និងការបន្តបំផ្លាញបេតិកភណ្ឌពិភពលោកប្រាសាទព្រះវិហារ ដោយបន្តរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាឆ្នាំ១៩៧២ ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌និងធម្មជាតិពិភពលោក និងអនុសញ្ញាឆ្នាំ១៩៥៤ ស្តីពីកិច្ចការពារសម្បត្តិវប្បធម៌ក្នុងពេលមានជម្លោះប្រដាប់អាវុធ ដែលរដ្ឋភាគីទាំងអស់នៃអនុសញ្ញានេះត្រូវគោរពយ៉ាងម៉ឺងម៉ាត់បំផុត ហើយទាមទារឱ្យថៃទទួលខុសត្រូវទាំងស្រុងចំពោះការរំលោភបំពានដ៏កំរោលនេះ។

ថ្ងៃចន្ទ ៣រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២៥

Unofficial Translation

STATEMENT

On the morning of 8 December 2025, at approximately 5:00 a.m., the Thai military launched an armed attack into Cambodian territory in the An Ses area of Preah Vihear Province, followed by additional shelling at Tamone Thom Temple and several other locations along the border using multiple types of heavy weaponry. Between 5:00 a.m. and 7:00 a.m., Thai forces continued their assaults in and around the immediate vicinity of the Temple of Preah Vihear, causing damage to the conservation building of the Gopura V Conservation and Restoration Project, implemented under Cambodia–India cooperation, as well as other essential conservation infrastructure at the site.

Since the inscription of the Temple of Preah Vihear on the UNESCO World Heritage List on 7 July 2008, Thailand has repeatedly fabricated claims and provoked armed confrontations in and around the temple—most notably between 2008 and 2011, and again during the renewed hostilities of 24–28 July 2025. The most recent attack occurred following several consecutive days of deliberate Thai military provocations, including the incident on 7 December 2025 at Prolean Thmor area within the Preah Vihear Temple Conservation Zone in Sra Em Commune, Choam Ksant District—acts clearly intended to incite confrontation and undermine the Kuala Lumpur Peace Agreement.

The Ministry of Culture and Fine Arts strongly condemns this renewed aggression, which has gravely obstructed ongoing conservation operations and forced the evacuation of officials, staff, guards, and conservation workers of the National Authority for Preah Vihear, as well as local residents. The Ministry denounces this blatant violation of the Joint Declaration on Peace between Cambodia and Thailand, signed by the Prime Ministers of both countries and facilitated and witnessed by U.S. President Donald J. Trump and Malaysian Prime Minister Anwar Ibrahim on 26 October 2025 in Kuala Lumpur.

The Ministry calls on Thailand to immediately cease all hostilities, which threaten peace, stability, and regional cooperation, and to fully and sincerely comply with the ceasefire agreement, the Joint Declaration on Peace, and all obligations under international law.

The Ministry further urges the international community to condemn Thailand's aggression against Cambodia's territorial integrity and the continuing destruction of the World Heritage Site of Preah Vihear—serious violations of the 1972 World Heritage Convention and the 1954 Hague Convention for the Protection of Cultural Property in the Event of Armed Conflict. As a State Party to these instruments, Thailand must be held fully accountable for these grave breaches.

Phnom Penh, 8 December 2025